**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៣៨ សហវ.ប្រក

# ប្រកាស
## ស្តីពី
## លក្ខណវិនិច្ឆ័យនៃការកាន់បញ្ជីគណនេយ្យមិនត្រឹមត្រូវ និងនីតិវិធីនៃការបង់ពន្ធអប្បបរមា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មជាបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងដាក់ចេញនូវការណែនាំអនុវត្តពន្ធអប្បបរមា។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះ មានគោលដៅកំណត់លក្ខណវិនិច្ឆ័យនៃអ្នកជាប់ពន្ធដែលកាន់បញ្ជិកាគណនេយ្យមិនត្រឹមត្រូវ និងរៀបចំនីតិវិធីក្នុងការបង់ពន្ធអប្បបរមា ស្របតាមមាត្រា២៤ថ្មី (ពីរ) នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ៣.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលប្រកបអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ ពាក្យ "បញ្ជិកាគណនេយ្យ" សំដៅដល់ សំណុំបញ្ជីគណនេយ្យ និងកំណត់ត្រាស្របតាមការតម្រូវរបស់អគ្គនាយកដ្ឋានពន្ធដារ និងស្របតាមស្តង់ដាគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ ៥.- លក្ខណវិនិច្ឆ័យនៃការកាន់បញ្ជិកាគណនេយ្យមិនត្រឹមត្រូវ**

សម្រាប់គោលដៅនៃប្រកាសនេះ ÷

១- លក្ខណវិនិច្ឆ័យនៃការកាន់បញ្ជិកាគណនេយ្យមិនត្រឹមត្រូវ មានដូចខាងក្រោម÷

- មិនបានកាន់កត់ត្រាបញ្ជីគណនេយ្យបានគ្រប់គ្រាន់តាមលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៤ នៃប្រកាសនេះ
- មិនបានចេញវិក្កយបត្រលើកិច្ចការជំនួញ ដូចមានចែងក្នុងមាត្រា៧៧ មាត្រា៧៨ មាត្រា៧៩ និងមាត្រា៩៨ នៃច្បាប់ស្តីពីសារពើពន្ធ
- បានប្រព្រឹត្តការក្លែងបន្លំធ្ងន់ធ្ងរ ដូចមានចែងក្នុងមាត្រា១២៦ នៃច្បាប់ស្តីពីសារពើពន្ធ
- បានធ្វើការគេចវេះពន្ធ ដូចមានចែងក្នុងមាត្រា១២៧ នៃច្បាប់ស្តីពីសារពើពន្ធ
- គ្មានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យ ក្នុងករណីសហគ្រាសដែលមានផលរបរលើសពី ២ ០០០ លានរៀលក្នុងមួយឆ្នាំ។

២- អគ្គនាយកដ្ឋានពន្ធដារត្រូវបង្កើតគណៈកម្មការវាយតម្លៃការកាន់បញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធ ដោយផ្អែកលើលក្ខណវិនិច្ឆ័យដូចមានចែងក្នុងកថាខណ្ឌ១ នៃប្រការនេះ។ ការវាយតម្លៃអ្នកជាប់ពន្ធណាមួយ ត្រូវធ្វើឡើងក្នុងរយៈពេល ២ ឆ្នាំម្តង និងជូនដំណឹងឱ្យអ្នកជាប់ពន្ធនោះបានដឹងជាមុននូវលទ្ធផលនៃការវាយតម្លៃ។

៣- អ្នកជាប់ពន្ធអាចស្នើសុំមកអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ឱ្យពិនិត្យឡើងវិញនូវការសម្រេចរបស់គណៈកម្មការវាយតម្លៃការកាន់បញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធ ក្នុងករណីអ្នកជាប់ពន្ធយល់ឃើញថាការសម្រេចមិនត្រឹមត្រូវ។

**ប្រការ ៦.- អ្នកជាប់ពន្ធដែលត្រូវលើកលែងឬត្រូវបង់ពន្ធអប្បបរមា**

សម្រាប់គោលដៅនៃប្រការនេះ ÷

១- អ្នកជាប់ពន្ធដែលទទួលបាននូវការវិនិច្ឆ័យថាបានកាន់បញ្ជីកាគណនេយ្យបានត្រឹមត្រូវ ត្រូវរួចផុតពីការបង់ពន្ធអប្បបរមា។

២- អ្នកជាប់ពន្ធដែលត្រូវបានចាត់ទុកថាមិនបានកាន់បញ្ជីកាគណនេយ្យបានត្រឹមត្រូវ ត្រូវមានកាតព្វកិច្ចបង់ពន្ធអប្បបរមា។

**ប្រការ ៧.- នីតិវិធីនៃការបង់ពន្ធអប្បបរមា**

នីតិវិធីនៃការបង់ពន្ធអប្បបរមាមានដូចខាងក្រោម ÷

១- អ្នកជាប់ពន្ធដែលកាន់បញ្ជីកាគណនេយ្យមិនត្រឹមត្រូវដូចមានកំណត់ក្នុងប្រការ៥ និងកថាខណ្ឌ២ នៃប្រការ៦ នៃប្រកាសនេះ ត្រូវជាប់ពន្ធអប្បបរមាតាមអត្រា ១ ភាគរយ នៃផលរបរប្រចាំឆ្នាំរួមបញ្ចូលទាំងពន្ធអាករនានាវៀរលែងតែអាករលើតម្លៃបន្ថែម ស្របតាមមាត្រា ២៤ថ្មី (ពីរ) នៃច្បាប់ស្តីពីសារពើពន្ធ។

២- ពន្ធអប្បបរមាត្រូវដល់កំណត់ត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ហើយអាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណូលដែលត្រូវបង់ជាក់ស្តែងក្នុងឆ្នាំជាប់ពន្ធនោះ តាមវិធានដូចមានចែងក្នុងមាត្រា ៣៧ថ្មី មាត្រា៣៨ និងមាត្រា៣៩ នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ៨.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ[illegible] ឆ្នាំ២០១៧

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

...ភ. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ